**៣- កសាងបណ្តាញការងារជាមួយដៃគូ :** ដើម្បីកសាងបណ្តាញការងារជាមួយអង្គការ និងស្ថាប័នពាក់ព័ន្ធនានាគាំទ្រដល់យុទ្ធសាស្ត្រនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ ។

**៤- ការរៀបចំស្ថាប័ន និងការគាំទ្រផ្នែកគោលនយោបាយ :** ដើម្បីបង្កើនសមត្ថភាពនៃស្ថាប័ន និងស្វែងយល់ពីបរិបទនយោបាយដែលមានឥទ្ធិពលលើការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមនៅថ្នាក់មូលដ្ឋាន ។

គំរោង CBNRM Initiative ផ្តោតការងារទៅលើការចូលរួមគ្រប់គ្រងធនធានធម្មជាតិតាមរយៈសកម្មភាពមួយចំនួន ដូចខាងក្រោម :

- គំរោងសហគមន៍ព្រៃឈើ
- សហការគ្រប់គ្រងលើធនធានជលផល
- ការធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម
- ការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួម
- ការគ្រប់គ្រងធនធានទឹកដោយមានការចូលរួម



# ផែនទីព្រំប្រទល់ដែននេសាទសហគមន៍ភូមិអន្លង់រាំង



**ឧបសម្ព័ន្ធទី ២ : ប្រវត្តិរបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍ជលផល CFDO**

ការិយាល័យ CFDO នៃនាយកដ្ឋានជលផលមានគោលដៅពង្រឹងនូវការបង្កើតសហគមន៍ជលផលអោយមានភាពរឹងមាំដោយសហគមន៍មូលដ្ឋានទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលធ្វើអោយសហគមន៍អាចមានលទ្ធភាព ដើម្បីធ្វើការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាពតាមរយៈកិច្ចសហការរបស់មន្ត្រីការិយាល័យ CFDO ទាំងនៅថ្នាក់ជាតិ និងមូលដ្ឋានជាមួយដៃគូការងារដើម្បីជួយបង្កើនជីវភាពរស់នៅរបស់សហគមន៍ មូលដ្ឋានដែលមានការពឹងផ្អែកលើធនធានជលផលក្នុងការចិញ្ចឹមជីវិត ។

យុទ្ធសាស្ត្រ និងផែនការអនាគតរបស់ការិយាល័យ CFDO ក៏ដូចជាសក្តានុពលក្នុងការសហការមានដូចខាងក្រោម :

**កិច្ចសហការទូទៅ :**

- បង្កើននូវទំនាក់ទំនង និងកិច្ចសហជាមួយនឹងការិយាល័យជលផលខេត្ត និងគំរោងសហគមន៍ជលផលនៅតាមបណ្តាខេត្តនានា
- បង្កើននូវការគាំទ្រនៅក្នុងនាយកដ្ឋានជលផល និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធលើការគ្រប់គ្រង សហគមន៍ជលផល
- ពង្រឹងការសំរបសំរួលជាមួយអង្គការជាតិ និងអន្តរជាតិដែលបានអនុវត្តការរៀបចំអនុវត្ត
- ពង្រឹងបន្ថែមនូវការសំរបសំរួលនូវសកម្មភាពនៃការអនុវត្តការងារគ្រប់គ្រងសហគមន៍ជលផលដោយគំរោង និងអ្នកផ្តល់ជំនួយផ្សេងៗ

**កិច្ចការច្បាប់ និងការប្រគល់អំណាច**

- ជំរុញអោយមានការចុះហត្ថលេខាលើពង្រាងអនុក្រឹត្យសហគមន៍ជលផល
- បង្កើតនូវគោលការណែនាំស្តីពីដំណើរការនៃការរៀបចំសហគមន៍ជលផល និងបទដ្ឋានច្បាប់ នានាទាក់ទងទៅនឹងទស្សនៈទានមួយចំនួន នៃអនុក្រឹត្យសហគមន៍ជលផលដូចជា លក្ខន្តិកៈ បទបញ្ញត្តិ បទបញ្ជា និងដំណើរការនៃការបោះឆ្នោតជ្រើសរើសគណៈកម្មាការសហគមន៍ជាដើម។
- សកម្មភាពផ្សព្វផ្សាយពីអនុក្រឹត្យសហគមន៍ជលផល

**ការរៀបចំសិក្សាស្រាវជ្រាវ**

- សិក្សាស្រាវជ្រាវពីដំណើរការនៃការរៀបចំសហគមន៍ជលផល :
  - ការរៀបចំបង្កើត និងអនុវត្តនូវគោលការណែនាំនៃផែនការគ្រប់គ្រងសហគមន៍ ជលផល
  - ស្វែងយល់ពីជំរើសនៃសកម្មភាពចិញ្ចឹមជីវិតដែលសហគមន៍ជលផលអាចអនុវត្តទៅបាន ដើម្បីកាត់បន្ថយភាពក្រក្រ និងធ្វើអោយមាននិរន្តរភាពនៃជីវភាពរស់នៅ

## ៤. សេចក្តីសន្និដ្ឋាន

កាលពីមុនការរស់នៅរបស់ប្រជាជនក្នុងភូមិអន្លង់រាំង មានការពឹងផ្អែកយ៉ាងខ្លាំងលើធនធានជលផលនៅក្នុងតំបន់នេះ ដើម្បីរកចំណូលសំរាប់ការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ។ ចាប់ពីឆ្នាំ១៩៨៧មក ធនធានជលផលនៅក្នុងតំបន់មានការថយចុះយ៉ាងខ្លាំងដោយសារតែការកាប់បំផ្លាញព្រៃលិចទឹក និងកំនើននៃការនេសាទ និងការប្រើប្រាស់ឧបករណ៍នេសាទពុំត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។ នាំអោយប្រាក់ចំណូលពីការនេសាទមានការធ្លាក់ចុះ ហើយជីវភាពរស់នៅរបស់អ្នកភូមិកាន់តែដុនដាបទៅ ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជាបានឧបត្ថម្ភគាំទ្រ ដោយមានការចូលរួមពីអ្នកភូមិក្នុងការរៀបចំបង្កើតសហគមន៍នេសាទនេះឡើង ។

ក្រោយពីបង្កើតសហគមន៍នេសាទ ប្រជាជនមានការយល់ដឹងពីសារៈសំខាន់ និងផលប្រយោជន៍ធនធានធម្មជាតិព្រមទាំងបានចូលរួមក្នុងការថែរក្សាការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានទាំងនេះឱ្យមានប្រសិទ្ធភាពតាមរយៈកម្មវិធីកសាងសមត្ថភាព កម្មវិធីគ្រប់គ្រងធនធានធម្មជាតិដែលបង្កើតឡើងដោយអង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា និងស្ថាប័នជំនាញ។ ជាលទ្ធផលបទល្មើសនេសាទ និងបទល្មើសផ្សេងៗទៀតបានថយចុះ ដែលជាហេតុធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើងម្យ៉ាងទៀតក្រោមកម្មវិធីលើកស្ទួយជីវភាពប្រជាជនក្នុងការបង្កើនមុខរបរគ្រួបផ្សំបានគាំទ្រជីវភាពរស់នៅរបស់ពួកគាត់ឱ្យមាននិរន្តរភាព។

មិនតែប៉ុណ្ណោះ ប្រការដែលគួរអោយកត់សំគាល់នោះ អ្នកភូមិមានការផ្លាស់ប្តូរជាវិជ្ជមានជាមួយនឹងការប្រសើរឡើងនៃជីវភាពរស់នៅរបស់ពួកគាត់ ព្រមទាំងការយល់ដឹងច្រើនអំពីបញ្ហាអំពើហឹង្សាក្នុងគ្រួសារតាមរយៈកម្មវិធីកសាងសមត្ថភាពបច្ចុប្បន្នស្ទើរតែពុំមានបញ្ហាអំពើហឹង្សានេះកើតឡើងនៅក្នុងភូមិឡើយ ។

## ៥. អនុសាសន៍

ដើម្បីជាការរួមចំណែកក្នុងការចូលរួមអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនិងជាការរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមសិក្សាស្រាវជ្រាវបានរៀបចំនូវអនុសាសន៍មួយចំនួនដូចខាងក្រោម ដើម្បីអោយអង្គការក៏ដូចជាស្ថាប័នជំនាញដែលជួយសម្របសម្រួលការងារគ្រប់គ្រងធនធានធម្មជាតិ ។ អនុសាសន៍មានដូចខាងក្រោមៈ

១. អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា គួរអនុញ្ញាតឱ្យសមាជិកសហគមន៍នេសាទមានសិទ្ធិខ្ចីប្រាក់ឥណទានបានចំនួនច្រើនជាងមុន ដើម្បីជួយពង្រីកមុខរបររបស់ពួកគាត់ឱ្យកាន់តែធំ ដើម្បីធ្វើឱ្យជីវភាពរស់នៅរបស់ពួកគាត់ ប្រសើរឡើងថែមទៀត ។

២. អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា គួរបង្កើតវគ្គបណ្តុះបណ្តាលខ្លីមួយអំពីការជួសជុលម៉ាស៊ីនកាណូតដល់សមាជិកសហគមន៍នេសាទ ព្រោះនៅក្នុងសហគមន៍របស់ពួកគាត់មានទូកប្រើម៉ាស៊ីន ច្រើនតែគ្មានជាងសម្រាប់ជួសជុលនៅពេលដែលម៉ាស៊ីនទូកខូចត្រូវយកទៅជួសជុលនៅតំបន់ឆ្ងាយៗ ជាហេតុធ្វើឱ្យពួកគាត់ចំណាយថវិកាច្រើន

៣. អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា និងការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផលគួរជួយផ្សព្វផ្សាយ ណែនាំ និងធ្វើការត្រួតពិនិត្យម្ចាស់ឡូតិ៍នេសាទឱ្យធ្វើការនេសាទទៅតាមសៀវភៅបន្ទុក និងកុំឱ្យឡូតិ៍នេសាទរំលោភបំពានចូលទៅក្នុងដែននេសាទរបស់សហគមន៍នេសាទ

៤. សំណូមពរឱ្យការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ នៃនាយកដ្ឋានជលផលជួយពង្រឹងសមត្ថភាព បន្ថែមដល់សមាជិកសហគមន៍នូវជំនាញនៃការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិក្នុងសហគមន៍នេសាទអោយមានស្ថេរភាព និងនិរន្តរភាព ។

## ៦. ឯកសារយោង


- របាយការណ៍សម្រង់ទិន្នន័យស្តីពីការគ្រប់គ្រង ថែរក្សាការពារ និងប្រើប្រាស់ធនធានដែលមាននៅក្នុងសហគមន៍, អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា (Cambodia Family Development Services) ឆ្នាំ ២០០១
- របាយការណ៍ទស្សនកិច្ចសិក្សា, ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ នាយកដ្ឋានជលផល ឆ្នាំ ២០០២

*បងប្រុស ប្រាក់ ផេង អាយុ៣៨ឆ្នាំ បច្ចុប្បន្នជាអ្នកភូមិអន្លង់រាំង:*
*ក្នុងគ្រួសារខ្ញុំមានសមាជិក ៥នាក់ ពីមុនពួកយើងរស់នៅឃុំកំពង់លួង ស្រុកក្រគរ ពួកយើងបានមករស់នៅភូមិអន្លង់រាំងនេះទើបជិតមួយឆ្នាំប៉ុណ្ណោះ។ ពីមុនគ្រួសារ ខ្ញុំប្រកបរបរនេសាទសុទ្ធសាធ ជីវភាពរបស់ខ្ញុំមានការលំបាកណាស់ ព្រោះនៅទីនោះមានការប្រកួតប្រជែងច្រើនចំពោះមុខរបរនេះ។ ដោយដឹងថាភូមិអន្លង់រាំង បានបង្កើតសហគមន៍នេសាទ និងផ្ដល់ឱកាសជាច្រើនដល់ប្រជាជនក្នុងការប្រកបរបរចិញ្ចឹមជីវិត គ្រួសាររបស់ខ្ញុំក៏បានមករស់នៅទីនេះ ហើយបានផ្លាស់ប្ដូរមុខរបរនេសាទទៅចាប់យកមុខរបរចិញ្ចឹមត្រី បញ្ចូលអាគុយ និងលក់ដូរ ដោយខ្ញុំបានដើមទុនពីប្រាក់កម្ចីឥណទានរបស់កម្មវិធីអង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា តាមរយៈសហគមន៍នេសាទ។ បច្ចុប្បន្នជីវភាពគ្រួសារខ្ញុំបានធូរធារច្រើនជាងមុន។*

*ភូមិអន្លង់រាំង ២០០៣*

### ៣.១.២ កម្មវិធីកសាងសមត្ថភាពដល់សហគមន៍



សកម្មភាពចិញ្ចឹមត្រីក្នុងបែរ របស់អ្នកភូមិអន្លង់រាំង

នៅភូមិអន្លង់រាំង ពុំដែលមានស្ថាប័នជំនាញ ជាពិសេសមន្ទីរអប់រំ ឬ អង្គការណាចុះទៅសម្របសម្រួល និងផ្ដល់ការបណ្ដុះបណ្ដាលផ្សព្វផ្សាយដល់ប្រជាជន និងកុមារក្នុងភូមិនេះឡើយ។ តាមការស្រង់ទិន្នន័យរបស់អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០០២ អ្នកដែលចេះអាន និងសសេរបន្តិចបន្តួចប្រមាណ២១%ប៉ុណ្ណោះ ចំណែកអនក្ខរជនវិញមានចំនួនដល់ទៅ៧៩% ជាទូទៅកុមារបានរៀនត្រឹមតែថ្នាក់ទី១-២ ។ នៅឆ្នាំ២០០២ អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា បានផ្ដល់សាលារៀនមួយខ្នងព្រមទាំងទំនាក់ទំនងជាមួយមន្ទីរអប់រំ និងមានគ្រូស្ម័គ្រចិត្តម្នាក់ជួយបង្ហាត់បង្រៀនដល់កុមារពីថ្នាក់ទី១ដល់ទី៣ លុះក្រោយមកបានទទួលគ្រូជាផ្លូវការមកពីមន្ទីរអប់រំ ។ ក្នុងនោះដែរ អង្គការបានបើកថ្នាក់អនក្ខរកម្មសំរាប់មនុស្សចាស់ និងអប់រំផ្សព្វផ្សាយការងារនានាដូចជាយេនឌ័រកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ និងការងារបរិស្ថានជាពិសេសបានទំនាក់ទំនងជាមួយមន្ទីរកសិកម្មស្នើរសុំមន្ត្រីជំនាញឱ្យចុះទៅបង្រៀនបច្ចេកទេសចិញ្ចឹមត្រី-ជ្រូកដល់ពួកគាត់ ។

*មុនពេលបង្កើតសហគមន៍នេសាទ ខ្ញុំមានជីវភាពលំបាកខ្លាំងណាស់ ដោយសារការនេសាទរបស់ខ្ញុំ មិនអាចយកមកផ្គត់ផ្គង់ជីវភាព ព្រោះរកចំណូលបានតិច និងចំណាយច្រើន។ ក្រោយពីបានបង្កើតសហគមន៍នេសាទ រូបខ្ញុំក៏ដូចជាប្រជាជនក្នុងភូមិដែរ បានចូលជាសមាជិកសហគមន៍នេសាទទាំងអស់។ កាលពីមុនខ្ញុំមានមុខរបរនេសាទត្រឹតែមួយមុខទេ ប៉ុន្តែឥឡូវនេះខ្ញុំមានមុខរបរគួបផ្សំផ្សេងទៀតដូចជា ចិញ្ចឹមត្រី និងចិញ្ចឹមជ្រូក ។ ខ្ញុំបានទទួលការបណ្ដុះបណ្ដាលពីសហគមន៍ចំពោះបច្ចេកទេសក្នុងការចិញ្ចឹមត្រី និងជ្រូក។ ខ្ញុំអាចទទួលបានប្រាក់កំរៃបន្ថែមពីមុខរបរទាំងនេះ ឥឡូវគ្រួសារខ្ញុំមានជីវភាពគ្រាន់បើជាងមុន នឹងអាចមានលទ្ធភាពទិញទូកម៉ាស៊ីនមកប្រើដូចគ្រួសារដទៃទៀតដែរ។*

*បងប្រុស ជិន ភី អាយុ៤១ឆ្នាំ*
*ភូមិអន្លង់រាំង ២០០៣*

### ៣.១.៣ កម្មវិធីគ្រប់គ្រង ថែរក្សា-ការពារ និងប្រើប្រាស់ធនធានក្នុងសហគមន៍

កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងអភិរក្សធនធានធម្មជាតិក្នុងភូមិអោយមាននិរន្តរភាពទៅពេលអនាគត។ ផែនការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍ រួមបញ្ចូលនូវគោលដៅ និងវិធានការចំពោះការការពារមានដូចជាៈ



ព្រៃលិចទឹក នៅភូមិអន្លង់រាំង

- អប់រំផ្សព្វផ្សាយ និងផ្តល់ចំណេះដឹងដល់ប្រជាជនពីសារៈប្រយោជន៍ធនធានធម្មជាតិ
- បង្កើតសហគមន៍ព្រៃលិចទឹក និងសហគមន៍នេសាទដើម្បីការពារជំរកមច្ឆាជាតិ
- ហាមដាច់ខាតនិងដាក់ទោស យ៉ាងធ្ងន់ធ្ងរចំពោះជនដែលចាប់សត្វព្រៃ និងប្រើប្រាស់ឧបករណ៍ នេសាទ ខុសច្បាប់ក្នុងការចាប់ត្រី
- ហាមបរបាញ់ និងយកពង-កូនសត្វនៅរដូវបន្តពូជ ។

បច្ចុប្បន្នអ្នកភូមិរៀនសូត្រចេះដឹងមានគំនិតច្នៃប្រឌិតក្នុងការគ្រប់គ្រង និងថែរក្សាការពារធនធានធម្មជាតិ ក្នុងភូមិបានល្អប្រសើរឡើង ។

### ៣.១.៤ កម្មវិធីអភិវឌ្ឍន៍សង្គមសង្គ្រោះ

កម្មវិធីនេះមានគោលបំណងជួយសំរួលដល់ជីវភាពប្រជាជនក្នុងសហគមន៍ដែលងាយនឹងរងគ្រោះ ដូចជាជនទីទាល់ក្រ ជនចាស់ជរាដែលគ្មានអ្នកជួយឧបត្ថម្ភគាំទ្រ ក្មេងកំព្រា ស្ត្រីមេម៉ាយទាល់ក្រ និងអ្នកមានជំងឺរ៉ាំរ៉ៃ ។ គោលការណ៍របស់អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា គឺជួយផ្តល់សម្ភារៈក្មេងរៀន សំលៀកបំពាក់សម្ភារៈ ប្រើប្រាស់ក្នុងផ្ទះ ជួសជុលផ្ទះ និងផ្តល់ស្បៀងអាហារ ។ បច្ចុប្បន្ន មានកម្មវិធីមួយទៀតគឺមូលនិធិសមធម៌ កម្មវិធីនេះ ជួយដល់ជនក្រីក្រដែល ពុំអាចមានលទ្ធភាពបង់សេវាពេទ្យ ។ ពេលមានជម្ងឺ អង្គការត្រូវ បង់ជូនទៅតាមគោលការណ៍ពេទ្យ (ជម្ងឺធម្មតាត្រូវបង់ ៣០០០០-៥០០០០រៀល ប្រសិនមានការវះកាត់ ត្រូវបង់ ១៨០០០០-២០០០០០រៀល ) ។

> *" គ្រួសារខ្ញុំបានមករស់នៅភូមិអន្លង់រាំង តាំងពីសម័យសីហនុមកម្ល៉េះ បច្ចុប្បន្នខ្ញុំរស់នៅតែពីរនាក់ប្តីប្រពន្ធព្រោះកូនបែកផ្ទះអស់ហើយ ។ គ្រួសារខ្ញុំប្រកបរបរនេសាទ និងចិញ្ចឹមត្រី ដោយកំលាំងចាស់រករបរអ្វីមិនសូវបានផល នាំឱ្យប្រាក់ចំណូលបានគ្រាន់តែហូប ហើយនៅពេលមានជំងឺ គ្មានលទ្ធភាពបង់សេវាពេទ្យ ។ ក្រោយពីបង្កើតសហគមន៍មកមានកម្មវិធី សង្គមសង្គ្រោះគ្រួសារខ្ញុំបានទទួលការឧបត្ថម្ភពីសហគមន៍ពេលមានជំងឺម្តងម្កាល ។"*
>
> *អ៊ំស្រី ប៊ុត យ៉ុម អាយុ៥៨ឆ្នាំ*
>
> *ភូមិអន្លង់រាំង ២០០៣*

កម្មវិធីនេះចង់ឱ្យជនក្រីក្របានចូលមកសម្រាកពេទ្យអាចមានលទ្ធភាពចូលរួមការងារក្នុងសង្គម និងការអភិវឌ្ឍន៍ផ្សេងៗបានដូចគ្រួសារដ៏ទៃទៀតដែរ។

គ្រួសារខ្ញុំបានមកតាំងទីលំនៅក្នុងភូមិអន្លង់រាំងពីឆ្នាំ១៩៩៧ ។ ពួកយើងប្រកបរបរចិញ្ចឹមជីវិតពឹងផ្អែកទៅលើការនេសាទតែមួយមុខ ។ ក្នុងពេលនោះដែរ មានជនល្មើសពីខាងក្រៅចូលមកធ្វើការនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ។ ទាំងនេះហើយជាឧបសគ្គដល់ការប្រកបរបរប្រចាំថ្ងៃ របស់គ្រួសារខ្ញុំក៏ដូចជាអ្នកភូមិទូទៅក្នុងការផ្គត់ផ្គង់គ្រួសារ។
បងស្រីតាន់ ណុច អ្នកភូមិអន្លង់រាំង ២០០៣



សកម្មភាពនេសាទខុសច្បាប់ដោយប្រើអួនក្រឡាញឹក

អ្នកភូមិភាគច្រើនដែលជាគ្រួសារក្រីក្របានត្អូញត្អែរថា ពួកគាត់មិនអាចរកត្រីបានច្រើនដូចមុនទេ ព្រោះកន្លែងនេសាទតូចចង្អៀតជាតំបន់ឡូតិ៍នេសាទហាមឃាត់ ។ អ្នកភូមិមួយចំនួនត្រូវបង្ខំចិត្តខ្ចីបុលពីឈ្មួញ និងអ្នកជិតខាងដើម្បីយកមកដោះស្រាយជីវភាព និងទិញឧបករណ៍នេសាទ។ ថ្វីត្បិតតែការខ្ចីបុលឈ្មួញមិនគិតអត្រាការប្រាក់ ប៉ុន្តែឈ្មួញបានធ្វើការកៀបសង្កត់មិនឱ្យអ្នកដែលខ្ចីលុយពីគេយកផលត្រីទៅលក់ឱ្យអ្នកផ្សេងទេ បើពុំនោះគេនឹងមិនអនុញ្ញាតឱ្យខ្ចីប្រាក់ពេលក្រោយឡើយ ម្យ៉ាងទៀតគឺត្រូវតែលក់ឱ្យម្ចាស់បំណុលក្នុងតំលៃថោកដើម្បីកាត់សងទៅនឹងប្រាក់កម្ចី ។ កំរៃដែលបានពីការលក់ផលិតផលនេសាទទៅអោយពួកឈ្មួញក្នុងតំលៃថោកនេះ តំរូវអោយប្រជានេសាទកាន់តែបង្កើនសកម្មភាពនេសាទដែលធ្វើអោយការនេសាទប្រព្រឹត្តទៅហួសលទ្ធភាព។

## ៣. ការផ្លាស់ប្តូរជីវភាពអ្នកភូមិអន្លង់រាំងក្រោយបង្កើតសហគមន៍នេសាទ

ក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលកម្ពុជា និងធ្វើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរួមបញ្ចូលការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន គឺជាមធ្យោបាយមួយដែលបានរួមចំណែកក្នុងការជំរុញអោយជីវភាពរស់នៅរបស់ប្រជាជនមានការកើនឡើង។

សហគមន៍ជលផលគឺ ជាយុទ្ធសាស្ត្រមួយនៃយុទ្ធសាស្ត្រជាច្រើនក្នុងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ក៏ដូចជាជួយសំរួលដល់ការបង្កើននូវប្រាក់ចំណូលរបស់ពួកគាត់។

### ៣.១. ជំរើសជាយុទ្ធសាស្ត្រក្នុងការប្រកបរបរចិញ្ចឹមជីវិត

ឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលលើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងក្រោមការស្នើសុំរបស់ប្រជាជនក្នុងភូមិអន្លង់រាំងក្នុងឆ្នាំ២០០២ អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជាបានសហការជាមួយស្ថាប័នជំនាញជលផលចុះមកសម្របសម្រួល ដើម្បីបង្កើតសហគមន៍នេសាទនៅក្នុងភូមិនេះ។ ក្នុងគោលបំណងដើម្បីស្តារធនធានធម្មជាតិនៅក្នុងភូមិ និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន

ក្នុងនោះដែរអង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជាក៏បានអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍មួយចំនួនដើម្បីសំរេចបាននូវគោលបំណងនេះ :

### ៣.១.១ កម្មវិធីឥណទានខ្នាតតូច




សកម្មភាពចិញ្ចឹមជ្រូករបស់អ្នកភូមិអន្លង់រាំង

កម្មវិធីឥណទានក្នុងសហគមន៍ផ្តល់តាមរយៈការឱ្យខ្ចីទុនយកទៅបង្កើនមុខរបរគ្រួបផ្សំដូចជាចិញ្ចឹម ត្រី ចិញ្ចឹមជ្រូក ទិញ-ជួសជុល ឧបករណ៍នេសាទ និងលក់ដូរជាដើម។ ដើម្បីអោយការប្រើប្រាស់ ឥណទានមានប្រសិទ្ធិភាព និងមាននិរន្តរភាពអង្គការបំរើគ្រួសារ អភិវឌ្ឍន៍កម្ពុជាបានផ្តល់ចំណេះដឹង និងបច្ចេកទេសលើការចិញ្ចឹមត្រី-ជ្រូក ដល់សមាជិកសហគមន៍នេសាទមុននឹងឱ្យខ្ចីទុន ។

<u>**យុទ្ធសាស្ត្រ និងនីតិវិធីក្នុងការផ្តល់ឥណទាន :**</u>

មានយុទ្ធសាស្ត្រពីរក្នុងការអភិវឌ្ឍន៍ឥណទានខ្នាតតូចក្នុងសហគមន៍:

១. អ្នកភូមិដែលក្រីក្របំផុតត្រូវបានផ្គត់ផ្គង់ និងផ្តល់ការបណ្តុះបណ្តាលអប់រំលើការចិញ្ចឹមត្រី និងចិញ្ចឹមជ្រូកពីមន្ត្រីជំនាញកសិកម្ម ដោយសហការជាមួយអង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជាមុនពេលផ្តល់ឥណទាន ។

២. អ្នកភូមិដែលខ្វះលទ្ធភាពក្នុងការចំណាយដើមទុនរកមុខរបរបន្ថែមដោយខ្លួនឯង ត្រូវបានផ្តល់ឥណទានពីអង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា តាមរយៈសហគមន៍នេសាទ។

ការផ្តល់ឥណទានត្រូវរៀបចំឱ្យខ្ចីតាមក្រុមតូចៗ ដែលមួយក្រុមមាន៣ទៅ ៥គ្រួសារ សមាជិកក្រុមនិមួយៗត្រូវមានការទទួលខុសត្រូវសងជំនួស ប្រសិនមានសមាជិកក្នុងក្រុមណាម្នាក់ក្លែងបន្លំ ។ ប្រាក់កម្ចីត្រូវបានផ្តល់ ៣០០,០០០រៀល សំរាប់រយៈពេល១០ខែ ដែលមានការប្រាក់៣% ក្នុង១ខែ ។ អត្រាការ ប្រាក់ដែលទទួលបានសហគមន៍យកមកបែងចែកក្នុងគោលបំណងបួនគឺ:

- ១០% លើកទឹកចិត្តគណៈកម្មការឥណទាន
- ១០% កម្មវិធីអភិវឌ្ឍន៍សង្គមសង្គ្រោះក្នុងភូមិ
- ៤០% បង្កើនទុនក្នុងសហគមន៍នេសាទ
- ៤០% យកទៅទប់ទល់នឹងការប្រាក់ឡើងចុះ

អ្នកខ្ចីឥណទានត្រូវមានកិច្ចសន្យាជាមួយអង្គការ បន្ទាប់ពីបញ្ចប់កិច្ចសន្យា ពួកគេនឹងត្រូវឱ្យខ្ចីបន្ថែមទៀតនៅដំណាក់កាលទីពីរ ។ មកទល់ពេលនេះកម្មវិធីឥណទានក្នុងភូមិមានចំនួនបីវគ្គកន្លងមក ហើយចំណែកឯប្រាក់គំកល់ក្នុង សហគមន៍នេសាទបានកើនឡើងដល់ចំនួនជាង ១១លានរៀល។

# ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពរបស់ប្រជាជនក្នុងសហគមន៍នេសាទភូមិអន្លង់រាំង

## ការបង្កើតសហគមន៍នេសាទភូមិអន្លង់រាំងបានជួយធ្វើអោយជីវភាពរបស់ប្រជាជនប្រសើរឡើង

## ១. សេចក្តីផ្តើម

ភូមិអន្លង់រាំង ជាភូមិបណ្តែតទឹកក្នុងព្រៃរនាមនៃបឹងទន្លេសាបដែលសំបូរដោយធនធានធម្មជាតិតាំងពីយូរលង់ណាស់មកហើយ ជាពិសេសជីវសាស្ត្រចំរុះធ្វើឱ្យសត្វរស់នៅក្នុងទឹករួមមានត្រី ថនិកសត្វអំបូរល្មូន អាចរស់នៅនិងបន្តពូជបានយ៉ាងងាយស្រួល ។ ក្នុងតំបន់នេះមានអាកាសធាតុក្តៅហើយសើមអាស្រ័យដោយមានព្រៃលិចទឹកបឹងបួរដែលជាជំរកធ្វើឱ្យពពួកសត្វដែលបានរៀបរាប់ខាងលើមានលក្ខណៈបន្សាំទៅនឹងកន្លែងរស់នៅរបស់វាជាប្រចាំ។ អ្នកភូមិរស់នៅលើផ្ទះបណ្តែតទឹកដែលអាចផ្លាស់ប្តូរទីលំនៅបានទៅតាមកំរិតទឹក តាមរដូវទឹកតំឡើង រឺរដូវទឹកសំរក ។

ភូមិនេះស្ថិតនៅក្នុងឃុំកំពង់ពោធិ៍ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មានផ្ទៃដីសរុប ១៥៨៧ហិកតាក្នុងនោះ ៤៦% គ្របដណ្តប់ដោយព្រៃលិចទឹក និង៥៤% គ្របដណ្តប់ដោយផ្ទៃទឹកនៃបឹងទន្លេសាប ( Tonle Sap Great Lake)។ មានប្រជាជនសរុបចំនួន៩១គ្រួសារ ក្នុងនោះ៥៥គ្រួសារជាជនជាតិខ្មែរ និង៣៦គ្រួសារទៀតជាជនជាតិវៀតណាម ។ ក្នុងចំណោមគ្រួសារទាំងអស់នោះមាន១គ្រួសារប្រកបមុខរបរជាអ្នកបញ្ចូលអាគុយ ២គ្រួសារលក់ដូរ និង៨៨គ្រួសារប្រកបរបរជាអ្នកនេសាទសុទ្ធសាធ និងរបរបន្ទាប់បន្សំដូចជាចិញ្ចឹមជ្រូក ចិញ្ចឹមត្រី (ក្នុងបែរ) និងទិញ/លក់ និងជួសជុលឧបករណ៍នេសាទ យោងតាមរបាយការណ៍សម្រង់ទិន្នន័យរបស់អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា (ឆ្នាំ២០០១)។

ចាប់ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ២០០១ មានអ្នកខាងក្រៅ និងអ្នកមានអំណាចមួយចំនួនបានធ្វើសកម្មភាពនេសាទយ៉ាងអាណាធិបតេយ្យក្នុងភូមិ ដោយពួកគេបានប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់បណ្តាលឱ្យធនធានជលផលមានការធ្លាក់ចុះយ៉ាងខ្លាំង។ ជាមួយគ្នានេះដែរប្រជាជនក្នុងភូមិមួយចំនួនតូចបានកាប់បំផ្លាញព្រៃលិចទឹក ដើម្បីយកមកប្រើប្រាស់សំរាប់តំរូវការប្រចាំថ្ងៃ ។ សកម្មភាពទាំងអស់នេះបានបំផ្លាញនូវធនធានធម្មជាតិអោយមានការថយចុះយ៉ាងខ្លាំង ជាពិសេសធនធានជលផលធ្វើអោយការប្រកបរបរចិញ្ចឹមជីវិតរបស់អ្នកភូមិលែងមាននិរន្តរភាព ។

ដោយមើលឃើញនូវភាពឱនថយនៃធនធានជលផលក្នុងតំបន់ នៅឆ្នាំ២០០២អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា ដោយមានកិច្ចសហការជាមួយការិយាល័យជលផលខេត្ត ធ្វើការសម្របសម្រួលជាមួយសហគមន៍មូលដ្ឋានក្នុងការបង្កើតអោយមានជាសហគមន៍ជលផល ដោយផ្តោតការយកចិត្តទុកដាក់លើការបង្កើនជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងក្នុងការថែរក្សាការពារធនធានធម្មជាតិ ។ ក្រោយពីបង្កើតសហគមន៍នេសាទ សកម្មភាពនេសាទល្មើសច្បាប់ត្រូវបានកាត់បន្ថយប្រជាជនក្នុងភូមិយល់ឃើញថាសហគមន៍នេសាទមានសារៈសំខាន់ណាស់ ព្រោះសហគមន៍នេសាទបានជួយឱ្យជីវភាពប្រចាំថ្ងៃរបស់ពួកគាត់បានប្រសើរឡើង និងគាំទ្រក្នុងការបង្កើននូវមុខរបរបន្ទាប់បន្សំរបស់ប្រជាជន ។

## ២. កត្តាមួយចំនួនដែលធ្វើអោយជីវភាពជួបការលំបាកមុនពេលបង្កើតសហគមន៍នេសាទ

### ២.១. ការថយចុះធនធានធម្មជាតិនៅភូមិអន្លង់រាំងដោយសារសកម្មភាពនេសាទអនាធិបតេយ្យ និងការបំផ្លាញព្រៃលិចទឹក

មុនឆ្នាំ១៩៨៧ នៅក្នុងភូមិអន្លង់រាំងសំបូរទៅដោយធនធានព្រៃលិចទឹក ធនធានត្រី និងធនធានសត្វព្រៃ ជាច្រើនប្រភេទដែលបានផ្តល់សារៈសំខាន់យ៉ាងខ្លាំងចំពោះប្រជាជនរស់នៅតំបន់នេះ ។ កំឡុងឆ្នាំ ១៩៨៧ ដល់២០០១ ធនធានទាំងនោះត្រូវបានថយចុះ និងបាត់បង់បន្តិចម្តងៗបណ្តាលអោយប្រាក់ចំណូលចំបងរបស់ប្រជាជនមានការធ្លាក់ចុះ ។ ការថយចុះនៃធនធានទាំងនោះ បណ្តាលមកពីកត្តាដូចជា:

- កាប់ព្រៃលិចទឹក ដើម្បីយកឈើធ្វើអុសដុត ធ្វើបែរចិញ្ចឹមត្រី ធ្វើឧបករណ៍នេសាទ
- ការដុតព្រៃដើម្បីចាប់សត្វ
- ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ (ឧបករណ៍ ឆក់ត្រី ឈិបយន្ត យ៉ាំងការ និងផ្ទុកជាដើម)

កត្តាទាំងនេះបានធ្វើអោយធនធានធម្មជាតិមានការថយចុះយ៉ាងខ្លាំងពិសេសពូជត្រីនិងទីជំរកសំរាប់ត្រីពងកូន ។ ប្រជាជនដែលមានមុខរបរជាអ្នកនេសាទជួបប្រទះនូវបញ្ហាខ្វះខាតយ៉ាងខ្លាំង ។ អ្នក



*សកម្មភាពកាប់ព្រៃលិចទឹកអាណាធិបតេយ្យ*

> *លោកម៉ៅ វណ្ណា អាយុ៤៥ឆ្នាំ រស់នៅភូមិអន្លង់រាំង បាននិយាយថា"កាលពីមុនខ្ញុំមានមុខរបរនេសាទតែមួយមុខគត់ ជីវភាពរបស់ខ្ញុំមានការលំបាកណាស់។ មានអ្នកខាងក្រៅ និងអ្នកមានអំណាចមួយចំនួនតូច ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ជាហេតុនាំឱ្យបាត់បង់ពូជត្រី និងបង្កផលវិបាកដល់អ្នកភូមិ ។ ព្រមទាំងការបំផ្លាញព្រៃលិចទឹក នាំឱ្យធនធានធម្មជាតិទាំងនោះកាន់តែថយចុះបន្តិចម្តងៗ និងពពួកសត្វព្រៃមួយចំនួនវិនាសផុតពូជ។"*
>
> ២០០៣

ភូមិមួយចំនួនទទួលស្គាល់ថាមានប្រជាជនតិចតួចណាស់ក្នុងភូមិដែលមានការយល់ដឹងពីសារៈប្រយោជន៍ព្រៃលិចទឹក មកពីពួកគាត់មានកំរិតយល់ដឹងទាប ។

### ២.២. មុខរបរនេសាទជាសកម្មភាពបង្កើតប្រាក់ចំណូលចំបងតែមួយមុខគត់

ជាទូទៅអ្នកភូមិអន្លង់រាំង មានមុខរបរជាអ្នកនេសាទត្រី ដែលជាមុខរបរចំបងរបស់ពួកគាត់ ។ ការ នេសាទជាលក្ខណៈគ្រួសារដោយប្រើប្រាស់ឧបករណ៍នេសាទមួយចំនួនដូចជា : មង សន្ទូច លប សំណាញ់ បង្កៃ និងស្នូរ ។ ជាទូទៅអ្នកភូមិពុំមានគំនិតក្នុងការថែរក្សា និងការពារធនធានធម្មជាតិទេ ដែលជាឱកាសដល់ជនល្មើសមួយចំនួនចូលមកធ្វើការនេសាទយ៉ាងអាណាធិបតេយ្យ ។ លើសពីនេះការពឹងផ្អែកលើមុខរបរនេសាទតែមួយមុខគត់ដើម្បីរកប្រាក់ចំណូល គឺជាសំពាធមួយយ៉ាងខ្លាំងទៅលើធនធានជលផល។ ដោយសារតំរូវការក្នុងគ្រួសារធ្វើអោយពួកគាត់បង្កើនសកម្មភាពនេសាទដោយប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីទាញយកផលនេសាទផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ។

# ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពរបស់ប្រជាជនក្នុងសហគមន៍នេសាទភូមិអន្លង់រាំង

**ករណីសិក្សា**

ភូមិអន្លង់រាំង ឃុំកំពង់ពោធិ៍ ស្រុកក្រគរ ខេត្តពោធិ៍សាត់


**ស្រាវជ្រាវ និងចងក្រងដោយៈ**

កែន សុភាព

រស់ ធារីវណ្ណ

ទិត ភារៈ

ហឿន ហុន្នី

នៅ ប៊ុនថា


២០០៤

ភូមិអន្លង់រាំង ជាភូមិបណ្តែតទឹកក្នុងព្រៃរនាមនៃបឹងទន្លេសាប ។ ភូមិនេះសំបូរដោយធនធានធម្មជាតិ និង ជីវៈចំរុះធ្វើឱ្យសត្វរស់នៅក្នុងទឹករួមមានត្រី ថនិកសត្វអំបូរល្មូនអាចរស់នៅនិងបន្តពូជបានយ៉ាងងាយស្រួល ។ អ្នកភូមិរស់នៅលើផ្ទះបណ្តែតទឹកដែលអាចផ្លាស់ប្តូរទីលំនៅបានទៅតាមការប្រែប្រួលរបស់កំរិតទឹក ។ ភូមិនេះមានប្រជាជនសរុបចំនួន៩១គ្រួសារ ក្នុងនោះ៥៥គ្រួសារជាជនជាតិខ្មែរ និង ៣៦គ្រួសារទៀតជាជនជាតិវៀតណាម ។ ចាប់ពីឆ្នាំ ១៩៨៧ ដល់ឆ្នាំ ២០០១ មានអ្នកខាងក្រៅ និង អ្នកមានអំណាចមួយចំនួនបានធ្វើសកម្មភាពនេសាទយ៉ាងអាណាធិបតេយ្យក្នុងភូមិ ដោយពួកគេបានប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់បណ្តាលឱ្យធនធានជលផលមានការធ្លាក់ចុះ ។ ជាមួយគ្នានេះដែរ ប្រជាជន ក្នុងភូមិមួយចំនួនតូចបានកាប់បំផ្លាញព្រៃលិចទឹក ដើម្បីយកមកប្រើប្រាស់សំរាប់តំរូវការប្រចាំថ្ងៃ ។ ជីវភាពរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិត របស់អ្នកភូមិលែងមាននិរន្តរភាព ។

ដោយមើលឃើញនូវភាពឱនថយនៃធនធានជលផលក្នុងតំបន់ នៅឆ្នាំ២០០២ អង្គការបំរើគ្រួសារ អភិវឌ្ឍន៍កម្ពុជាក្រោម កិច្ចសហការជាមួយការិយាល័យជលផលខេត្ត ធ្វើការសម្របសម្រួលជាមួយសហគមន៍មូលដ្ឋានក្នុងការបង្កើតអោយមានជាសហគមន៍ជលផល ។ ករណីសិក្សានេះនឹងបង្ហាញអោយឃើញពីភាពជោគជ័យនៃការរៀបចំបង្កើតសហគមន៍ជលផលនៅក្នុងតំបន់នេះ ។

ក្រោយពីបង្កើតសហគមន៍នេសាទ ប្រជាជនមានការយល់ដឹងពីសារៈសំខាន់ និងផលប្រយោជន៍ធនធានធម្មជាតិ ព្រមទាំងបានចូលរួមក្នុងការថែរក្សា-ការពារគ្រប់គ្រង និងប្រើប្រាស់ធនធានទាំងនេះឱ្យមានប្រសិទ្ធិភាពតាមរយៈ កម្មវិធីកសាងសមត្ថភាពកម្មវិធីគ្រប់គ្រងធនធានធម្មជាតិដែលបង្កើតឡើង

ដោយអង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា និងស្ថាប័នជំនាញ ។ ជាលទ្ធផលបទល្មើសនេសាទ និងបទល្មើសផ្សេងៗទៀតបានថយចុះ ដែលជាហេតុធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើងលើសពីនេះទៀត ក្រោមកម្មវិធីលើកស្ទួយជីវភាពប្រជាជនក្នុងការបង្កើនមុខរបរគួបផ្សំបានគាំទ្រជីវភាពរស់នៅ របស់ពួកគាត់ឱ្យមាននិរន្តរភាព ។ ប្រជាជនក្នុងភូមិយល់ឃើញថា ការរៀបចំបង្កើតសហគមន៍មានសារៈសំខាន់ណាស់ ដោយសារតែសកម្មភាពនេះបានធ្វើអោយជីវភាពរស់នៅរបស់ពួកគាត់មានភាពប្រសើរ ឡើងអ្នកភូមិមានការផ្លាស់ប្តូរជាវិជ្ជមានជាមួយនឹងការប្រសើរឡើងនៃជីវភាពរស់នៅរបស់ពួកគាត់ ។

**ស្រាវជ្រាវ និងចងក្រងដោយៈ**

*កែន សុភាព*

CBNRM Initiative/WWF

*រស់ ធរីវ័ណ្ណ*

អ្នកគាំទ្រក្រុមសហគមន៍ខេត្តបាត់ដំបង

*ទិត ភារៈ*

ការិយាល័យអភិវឌ្ឍន៍សហគមន៍

*ហឿន ហុន្នី*

CFDS ខេត្តពោធិ៍សាត់

*នៅ ប៊ុនថា*

**កែសំរួលដោយៈ**

*ហ៊ួ កល្យាណ*

ទីប្រឹក្សាថ្នាក់ជាតិ គំរោង CBNRM LI

*យែនន៉ែត រីប*

*ស្តែប ខក់*

**ឧបត្ថម្ភថវិកាដោយអង្គការ**

CBNRM Learning Initiative / WWF

# អារម្ភកថា
## ដំណើរការនៃការចងក្រងករណីសិក្សា

គំរោងករណីសិក្សាស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន CBNRM Initiative បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីផ្តល់ជំនាញគ្រឹះសំរាប់ការសិក្សាស្រាវជ្រាវ ដោយប្រើប្រាស់វិធីសាស្ត្រការវាយតំលៃជនបទដោយមានការចូលរួម (PRA) ការវិភាគពត៌មាន ការសរសេរ អត្ថបទ និងចងក្រងឯកសារ ។ ដោយមានការកើនឡើងនូវតំរូវការពីបណ្តាដៃគូក្នុងការចងក្រងនូវបទពិសោធន៍ និងមេរៀនសំខាន់ដែលបានអនុវត្តក្នុងការការងារគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម គំរោង CBNRM Initiative បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីករណីសិក្សាចំនួនបីលើករួចមក ហើយដោយមានកិច្ចសហការពីបណ្តាដៃគូរបស់គំរោង CBNRM Initiatived ទៃទៀត ។

វគ្គបណ្តុះបណ្តាលលើកទី១ បានរៀបចំនៅខេត្តសៀមរាប កាលពីខែកក្កដា ឆ្នាំ២០០១ ។ វគ្គបណ្តុះបណ្តាលនេះមានការចូលរួមពីអ្នកពាក់ព័ន្ធមួយចំនួនដើម្បីពិភាក្សាគ្នាពីបទពិសោធន៍ និងវិភាគលើទស្សនៈទានស្តី ពីការគ្រប់គ្រងធនធានធម្មជាតិ និងរៀនសូត្រពីរបៀបនៃការចងក្រងករណីសិក្សាដោយប្រើប្រាស់នូវជំហ៊ានទាំង ១០នៅក្នុងសៀវភៅណែនាំស្តីពីការចងក្រងករណីសិក្សា ។ របាយការណ៍ស្តីពីដំណើការដែលហៅថា *"រឿងរ៉ាវ នៅតំបន់ទន្លេសាប"* និងការកែសំរួលលើសៀវភៅណែនាំស្តីពីការចងក្រងករណីសិក្សាបានរៀបចំចងក្រង និងកែសំរួលក្រោយពីបានរៀបចំវគ្គបណ្តុះបណ្តាលនៅខេត្តរតនៈគីរីកាលពីខែ វិច្ឆិកា ឆ្នាំ ២០០១ ។ វគ្គបណ្តុះបណ្តាលនេះបានរៀបចំចងក្រង *"រឿងរ៉ាវនៅតំបន់ខ្ពង់រាបនៃខេត្តរតនគីរី"* របាយការណ៍ករណីសិក្សា និងការកែសំរួលលើសៀវភៅណែនាំបានរៀបចំចងក្រងឡើង ។

កាលពីខែ ឧសភា ឆ្នាំ ២០០២ គំរោង CBNRM Initiative បានសហការជាមួយគំរោងដៃគូនៅមូលដ្ឋានរៀបចំសិក្ខាសាលាបូកសរុបមួយនៅខេត្តកោះកុងដើម្បីពិនិត្យ និងកែសំរួលលើលទ្ធផលនៃករណីសិក្សាជាមួយដៃគូការងារ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ។ នៅខែ វិច្ឆិកា ឆ្នាំ ២០០២ សិក្ខាសាលាថ្នាក់ជាតិស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមនៅភ្នំពេញបានរៀបចំដើម្បីបង្ហាញពីលទ្ធផល និងបទពិសោធន៍ដែល បានចងក្រងនៅក្នុងករណីសិក្សាទាំងនោះ និងក្នុងគោលបំណងដើម្បីចាប់ផ្តើមរៀបចំជំហ៊ានបន្ទាប់សំរាប់អនុវត្តសកម្មភាពនៃ CBNRM នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្នុងខែ តុលា ឆ្នាំ ២០០៣ គំរោង CBNRM Initiative ក្នុងកិច្ចសហការជាមួយគំរោងគ្រប់គ្រងតំបន់ឆ្នេរដោយមានការចូលរួម និងគំរោងសិក្សាស្រាវជ្រាវ សហគមន៍ព្រៃឈើនៅកម្ពុជាបានរៀបចំបើកវគ្គបណ្តុះបណ្តាលលើកទី ៣ ស្តីពីករណីសិក្សានៅភ្នំពេញ ។ ប្រធានបទសំខាន់ៗនៅតាមតំបន់មួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានលើកយកមកពិភាក្សា និងចងក្រងដោយសិក្ខាកាមដែលបានចូលរួមពីស្ថាប័នផ្សេងៗ ។ នៅថ្នាក់តំបន់ មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើ ថ្នាក់

តំបន់ (RECOFTC) បានរៀបចំវគ្គបណ្តុះបណ្តាលចំនួនពីរលើកនៅប្រទេសថៃឡង់ត៍ ។ ក្រោយពីបានចូលរួមវគ្គបណ្តុះបណ្តាលលើកទី២ ករណីសិក្សាស្តីពីបញ្ហាជីសម្បទានដើម្បីកាត់បន្ថយភាពក្រីក្របានរៀបចំចងក្រងឡើង ។ សៀវភៅណែនាំស្តីពីការចងក្រងករណីសិក្សាដែលបានរៀបចំដោយគំរោង CBNRM Initiative ត្រូវបានទទួលយកទៅអនុវត្ត និងរៀបចំកែសំរួលដើម្បីប្រើប្រាស់នៅថ្នាក់តំបន់ដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់ ។

តាមរយៈវគ្គបណ្តុះបណ្តាល និងក្នុងដំណើរការនៃការចុះសិក្សាស្រាវជ្រាវចងក្រងនូវករណីសិក្សានេះ បានផ្តល់ឱកាសដល់សិក្ខាកាមបានរៀនសូត្រនូវជំនាញ និងបទពិសោធន៍ពីគ្នាទៅវិញទៅមក និងជាពិសេសបានផ្តល់ជាឱកាសក្នុងការកសាងនូវបណ្តាញការងារដើម្បីពង្រឹងនូវការគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ជាពិសេសទៅទៀត លទ្ធផលនៃករណីសិក្សានេះនឹងប្រើប្រាស់ជាឯកសារជំនួយស្មារតីដ៏សំខាន់ ដោយអ្នកសិក្សាស្រាវជ្រាវ និងអ្នកអនុវត្តការងារគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមបានរៀនសូត្រនូវបទពិសោធន៍មេរៀនផ្សេងៗ ដែលទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជាដើម្បីបង្កើន នូវប្រភេទផ្សេងៗនៃការគ្រប់គ្រងធនធានធម្មជាតិ ហើយអាចអនុវត្តនូវមេរៀនទាំងនេះនៅតំបន់ដទៃទៀតប្រកបដោយប្រសិទ្ធិភាព ។

អត្ថន័យដែលបានបកស្រាយបង្ហាញនៅក្នុងករណីសិក្សានេះ គឺជាលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ក្រុមដែលបានធ្វើការសិក្សាស្រាវជ្រាវនៅមូលដ្ឋាន ហើយអត្ថបទនេះមិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់គំរោង CBNRM Initiative ឬដៃគូដែលបានផ្តល់ជំនួយនោះទេ ។

# មាតិកា

## ការបង្កើតសហគមន៍នេសាទភូមិអន្លង់រាំងបានជួយធ្វើអោយជីវភាពរបស់ប្រជាជនប្រសើរឡើង


១. សេចក្តីផ្តើម..........................................................................................១

២. កត្តាមួយចំនួនដែលធ្វើអោយជីវភាពជួបការលំបាកមុនពេលបង្កើតសហគមន៍នេសាទ............២

២.១ ការថយចុះធនធានធម្មជាតិនៅភូមិអន្លង់រាំងដោយសារសកម្មភាពនេសាទអនាធិបតេយ្យ និងការបំផ្លាញព្រៃលិចទឹក..........................................................................................២

២.២ មុខរបរនេសាទជាសកម្មភាពបង្កើតប្រាក់ចំណូលចំបងតែមួយមុខគត់......................២

៣. ការផ្លាស់ប្តូរជីវភាពអ្នកភូមិអន្លង់រាំងក្រោយបង្កើតសហគមន៍នេសាទ.............................៣

៣.១ ជំរើសជាយុទ្ធសាស្ត្រក្នុងការប្រកបរបរចិញ្ចឹមជីវិត..............................................៣

៣.១.១ កម្មវិធីឥណទានខ្នាតតូច.................................................................៤

៣.១.២ កម្មវិធីកសាងសមត្ថភាពដល់សហគមន៍...................................................៥

៣.១.៣ កម្មវិធីគ្រប់គ្រង ថែរក្សា-ការពារ និងប្រើប្រាស់ធនធានក្នុងសហគមន៍..............៦

៣.១.៤ កម្មវិធីអភិវឌ្ឍន៍សង្គមសង្គ្រោះ...........................................................៦

៤. សេចក្តីសន្និដ្ឋាន......................................................................................៧

៥. អនុសាសន៍..........................................................................................៧

៦. ឯកសារយោង.......................................................................................៨

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ : ផែនទីព្រំប្រទល់ដែននេសាទសហគមន៍ភូមិអន្លង់រាំង

ឧបសម្ព័ន្ធទី២ : ប្រវត្តិរបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍ផលផល CFDO

ឧបសម្ព័ន្ធទី៣ : ប្រវត្តិគំរោង CBNRM

ICSF
FOR DIGITIZATION
DATE: 02/11/2018

911/MO